# តុក្កតាក្រណាត់

ទោះជាប្រទេសណាក៏ដោយក៏មានតុក្កតាដែលបង្ហាញអំពីលក្ខណៈពិសេសរបស់ប្រទេសនោះទាំងពីបុរាណកាលមកដែរ ។ ចំណែកឯតុក្កតាដែលផលិតដោយដៃនេះក៏ត្រូវបានផលិតតាមលក្ខណៈពិសេសរបស់ខ្មែរដែរ ។ ដូច្នេះសូមបង្ករឱកាសឱ្យកុមារលេងដោយសេរីម្នាក់ៗ ឬលេងជាក្រុមជាមួយមិត្តភ័ក្តិ ឱ្យសមនឹងការអភិវឌ្ឍន៍របស់កុមារទៅតាមអាយុរបស់ពួកគេ ។

តាមដំណាក់កាលលូតលាស់របស់កុមារកុមារ ពេលកុមារមានអាយុលើសពី២ឆ្នាំ កុមារមានការអភិវឌ្ឍន៏សមត្ថភាពឆ្នៃប្រឌិត ។ មានន័យថា ទោះជាមិនមានរបស់នៅនឹងមុខក៏កុមារអាចធ្វើត្រាប់លេងបានដែរ ។ ឧទាហរណ៍ កុមារយកស្លឹកឈើដាក់ចូលក្នុងចានធ្វើជាបាយដោយដើរ តួជាម្តាយ ហើយនិយាយទៅកាន់តុក្កតា បញ្ចុកបាយឱ្យតុក្កតា សិតសក់ឱ្យតុក្កតា ធ្វើម្ហូបជាដើម ។ល ។ ទាំងនេះហៅថា "ជ្រុង តុក្កតា" ។ ការលេងកំសាន្តនៅជ្រុងតុក្កតា កុមារអាចលេងជាមួយមិត្តភ័ក្តិ ហើយពង្រីកគ្នាច្រើនឡើងៗ ដោយស្ថិតក្នុងស្ថានភាពស្មុគស្មាញបែបនេះ កុមារអាចយល់អំពីតួនាទីរបស់ខ្លួន ហើយមានការលូតលាស់ទាំងភាសា ទាំងសង្គម វិទ្យា ។
មានន័យថាបទពិសោធន៍នីមួយៗរបស់កុមារគឺជាមូលដ្ឋានគ្រឹះនៃចំណេះដឹង ដែលធ្វើឱ្យកុមារយល់ ដឹងអំពីពាក្យ ភាសា អក្សរ លេខ ជាដើម ។ ឧទាហរណ៍ ពេលឮគ្រូនិយាយថា"ផ្លែស្វាយ" ទោះជាមិនបានឃើញផ្លែស្វាយផ្ទាល់ក៏កុមារអាចដឹងបាន ដែរ ។ ការអាននិងស្តាប់ ពាក្យ"ផ្លែស្វាយ" ធ្វើឱ្យកុមារដឹងថាវាមានពណ៌បៃតង ហើយមានរសជាតិជូរអែម ។ ហើយនៅពេលនិយាយពាក្យ"ស្វាយកែវចិន" តាមបទពិសោធន៍ដ៏សម្បូរបែបធ្វើឱ្យកុមារអាចដឹងថា ជាឈ្មោះ ផ្លែស្វាយម្យ៉ាង ក្នុងចំណោមផ្លែស្វាយទាំងអស់ ។

[គោលបំណង]

១. ចង់ឱ្យកុមារបានកាន់លេងបណ្តើរ និងជួយឱ្យកុមារអាចសំដែងអំពីខ្លួនឯងបណ្តើរ ។
២. ធ្វើឱ្យកុមារមានការលូតលាស់ផ្នែកភាសា ។
៣. បង្កើតចំណេះដឹងផ្នែកសង្គមវិទ្យា ។
៤. ធ្វើឱ្យកុមារមានការអភិវឌ្ឍន៏ផ្នែកមនោសញ្ចេតនា ។

[របៀបបង្ហាញទៅកុមារ]

១. សូមបង្កើតជ្រុងតុក្កតា ដើម្បីឱ្យកុមារលេងដោយសេរី ហើយជ្រុងតុក្កតាត្រូវបង្កើតក្នុងបរិយាកាសមួយដែលអាចឱ្យកុមារធ្វើសកម្មភាពបានងាយស្រួល ។

២. សូមគ្រូចូលទៅជ្រុងតុក្កតាម្តងម្កាល ដើម្បីពិនិត្យមើលការប្រែប្រួលតាមរយៈការលេងរបស់កុមារ ហើយសូមលេងជាមួយកុមារដែលមានបទពិសោធន៍តិច និងកុមារដែលមិនសូវចេះនិយាយស្ដី ដើម្បីឱ្យពួកគេអាចសំដែងអំពីខ្លួនគេបាន។

[ចំណុចត្រូវប្រុងប្រយ័ត្ន]

១. សូមចាប់អារម្មណ៍ចំពោះកុមារដែលប្រើអំពើហឹង្សាដាក់តុក្កតា ពីព្រោះនៅក្នុងជ្រុងតុក្កតា កុមារបង្ហាញឱ្យនូវអ្វីដែលគេបានឃើញ បានឮ និងបទពិសោធន៍របស់គេ ដូច្នេះយើងអាចថ្លឹងថ្លែងដឹងអំពីស្ថានភាពគ្រួសាររបស់គេបានតាមរយៈការលេងរបស់គេ។

[ចំណុចល្អរបស់តុក្កតាក្រណាត់]

១. មានភាពកក់ក្តៅដោយសារការផលិតដោយដៃ

២. អាចផលិតដោយដៃបាន

៣. អាចប្រើប្រាស់ក្នុងការពន្យល់អំពីផ្នែកមួយៗនៃសារពាង្គកាយទាំងមូលបាន។









